IOM
UN MIGRATION

# ជំនួយសម្រាប់ពលករចំណាកស្រុកស្តីអំពីសិទ្ធិ ហៀតទៅដល់សេរីភាពខាងសមាគម និងការចរចាជាសមូហភាពនៅក្នុងប្រទេសថៃ



CREST FASHION

CREST
CORPORATE RESPONSIBILITY
IN ELIMINATING SLAVERY AND TRAFFICKING

ឯកសារនេះត្រូវបានបង្កើតឡើងដោយក្របខណ្ឌពីគម្រោងមួយឈ្មោះ ពង្រឹងទំនួលខុសត្រូវដែលមានការចូលរួម ដើម្បីលុបបំបាត់ការកេងប្រវ័ញ្ចកំលាំងពលកម្ម ទាសភាព និងការជួញដូរមនុស្ស (CREST) និង គម្រោង CREST Fashion។

## តើខ្ញុំមានសិទ្ធិសេរីភាពក្នុងការចូលជាសមាគម និងការចរចាជាសមូហភាពទេនៅក្នុងប្រទេសថៃ ?

**មាន!** ពលករចំណាកស្រុកត្រូវបានអនុញ្ញាតឱ្យចូលជាសមាជិក និងចូលរួមក្នុងសកម្មភាពសហជីពនៅប្រទេសថៃ។ ទោះយ៉ាងណាក៏ដោយ ច្បាប់ថៃមិនអនុញ្ញាតឱ្យពលករចំណាកស្រុកក្លាយជាសមាជិកក្រុមក្រុមប្រឹក្សាភិបាល ឬជាអ្នកកាន់កាប់ការិយាល័យដែលចុះបញ្ជីជាសហជីព ឬសហជីពការងារទេ។ នេះមានន័យថា៖



- អ្នកមានសេរីភាពក្នុងការជួបនិងភ្ជាប់ទំនាក់ទំនងជាមួយតំណាងមកពីសហជីពនិង/ឬអង្គការរបស់ ពលករនៅកន្លែងធ្វើការរបស់អ្នក។



- អ្នកមានសេរីភាពក្នុងការចូលរួមក្នុងកិច្ចប្រជុំសហជីពដោយមិនចាំបាច់មានវត្តមានពីអ្នកគ្រប់គ្រងរបស់ក្រុមហ៊ុន។



- អ្នកមិនគួរត្រូវបានដាក់ទណ្ឌកម្ម បំភិតបំភ័យ ឬយាយីពីនិយោជករបស់អ្នកចំពោះការចូលរួមសហជីព ចូលរួមសកម្មភាពណាមួយដែលជាប់ទាក់ទងនឹងសហជីពឬអង្គការរបស់ពលករឬសម្រាប់តំណាងផលប្រយោជន៍រួមរបស់ពលករ។



- អ្នកមិនគួរត្រូវបានដាក់ទណ្ឌកម្មចំពោះការចូលរួមក្នុងជម្លោះផលប្រយោជន៍រួម ការបញ្ឈប់ការងារ ឬការធ្វើកូដកម្ម យោងទៅតាមច្បាប់របស់ប្រទេសថៃ។



- កិច្ចសន្យាការងាររបស់អ្នកមិនគួរត្រូវបានបញ្ចប់ទេប្រសិនបើអ្នកចូលរួមក្នុងសកម្មភាពដែលទាក់ទងនឹងការចរចាសមូហភាពសហជីព ឬអង្គការរបស់ពលករ។




- និយោជករបស់អ្នកមិនគួរផ្តល់ការលើកទឹកចិត្តដើម្បីរារាំងអ្នកមិនឱ្យចូលរួមសហជីព ឬចូលរួមក្នុងសកម្មភាពសហជីពទេ ។

INFO

## តើសហជីព និងអង្គការពលករជាអ្វី ?

សហជីព និងអង្គការរបស់ពលករដើរតួនាទីយ៉ាងសកម្មក្នុងការចរចាសមូហភាពរវាងនិយោជក និងពលករ ដើម្បីចរចាលក្ខខណ្ឌការងារ សុខុមាលភាព អត្ថប្រយោជន៍ និងដោះស្រាយវិវាទការងារដោយសន្តិវិធីសម្រាប់កន្លែងធ្វើការប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាព។

## តើការចរចាជាសមូហភាពគឺជាអ្វី ?

ដំណើរការដែលពលករ តាមរយៈសហជីព ចរចាលក្ខខណ្ឌការងារជាមួយនិយោជករួមមាន ប្រាក់ឈ្នួល អត្ថប្រយោជន៍ ម៉ោងការងារ ឈប់សម្រាក សុខភាពការងារ គោលនយោបាយសុវត្ថិភាព និងច្រើនទៀត។

លទ្ធផលនេះត្រូវបានផ្តល់មូលនិធិដោយ
ក្រុមហ៊ុនផ្គត់ផ្គង់អាយគារ ព្រមទាំង៖

Laudes Foundation

Sweden Sverige

អាយអូអិមប្រទេសថៃ, ជាន់ទី១៨, អាគារ រ៉ាចាណាកាន, ផ្លូវសាថនខាងត្បូង៣, បាំងកក ១០១២០, ប្រទេសថៃ
ទំនាក់ទំនង៖ (+៦៦) ២ ៣៤៣ ៩៣០០ (ការិយាល័យកណ្តាល) អ៊ីម៉ែល៖ crestthailand@iom.int